ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តស្វាយរៀង
គណៈកម្មាធិការលទ្ធកម្មរដ្ឋបាលខេត្ត
លេខ : ០០៣.៣/១៨ ស.ជ.ណ

# សេចក្តីជូនដំណឹង

លទ្ធកម្មរដ្ឋបាលខេត្តស្វាយរៀង

ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់
## សម្ភារិមសម្រាប់ឆ្នាំ២០១៨

រដ្ឋបាលខេត្តស្វាយរៀង សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា៖ រដ្ឋបាលខេត្តស្វាយរៀង នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់ សម្ភារិម សម្រាប់ឆ្នាំ២០១៨ ។

រដ្ឋបាលខេត្តស្វាយរៀង បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តស្វាយរៀង អាសយដ្ឋានសាលាខេត្តស្វាយរៀង ចាប់ពីថ្ងៃច័ន្ទ ១០កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៨ រៀងរាល់ម៉ោងធ្វើការ ដល់វេលាម៉ោង ០៨ និង ៣០នាទី ថ្ងៃ អង្គារ ១០កើត ខែពិសាខ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៨។

ឯកសារដេញថ្លៃ ដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មរដ្ឋបាលខេត្ត យ៉ាងយូរបំផុតម៉ោង ០៨ និង៣០នាទី ថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំរកានព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៨ ។

ការបើកឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មរដ្ឋបាលខេត្ត តាមអាសយដ្ឋានខាងលើ (សាលាខេត្តស្វាយរៀង) វេលាម៉ោង០៨ និង៣០នាទីព្រឹក ថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំរកានព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ សុក្រ ០៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅស្វាយរៀង, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៨

ជ. អភិបាលខេត្ត និងជា

ជ. ប្រធានគណៈកម្មាធិការលទ្ធកម្មរដ្ឋបាលខេត្ត

ប្រាក់_សុវណ្ណ

**ចម្លងជូន៖**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារកាលប្បវត្តិ